FARMER NOTES

ព្រឹត្តិប័ត្រព័ត៌មានកសិករ

ការចេញផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
A Publication of the Cambodian Agricultural Research and Development Institute



# ការបោកស្រូវ

## អ្វីទៅជាការបោកស្រូវ ?

ការបោកស្រូវ គឺជាផ្នែកមួយនៅក្នុងដំណើរការប្រមូលផល ។ ការប្រមូលផលស្រូវ គឺជាដំណើរការប្រមូលយកនូវផ្នែកដែលទុំ (មានប្រយោជន៍) នៃដំណាំស្រូវពីក្នុងស្រែ រួមមាន៖ ការច្រូតកាត់ ការលើកដាក់និងដឹកជញ្ជូន ការហាលសម្ងួតដៃ /កណ្តាប់នៅវាលស្រែ ការទុកដាក់ឬការគរកណ្តាប់ជាស្នឹម ការបោកបែន ការរោយសម្អាត ការវេចខ្ចប់ និងការដឹកជញ្ជូនគ្រាប់ស្រូវទៅឃ្លាំង ។

## ហេតុអ្វីបានជាការបោកសមស្រប និងទាន់ពេលវេលាមានសារៈសំខាន់ ?

ការខកខាន (ពន្យារពេល) បោកបែនបន្ទាប់ពីច្រូតកាត់រួច ធ្វើឱ្យគ្រាប់ស្រូវខូចយ៉ាងឆាប់រហ័ស ជាពិសេស នៅពេលហាល ឬគរកណ្តាប់ជាស្នឹមនៅវាលស្រែ ។ ការបោកមិនបានសមស្របអាចបណ្តាលឲ្យបាត់បង់ច្រើនដោយសារការបោក និងការកំពប់ខ្ចាត់ខ្ចាយ ។

## វិធីសាស្ត្របោកស្រូវ

ការបោកស្រូវ គឺជាការផ្តាច់យកគ្រាប់ស្រូវចេញពីដើម (ចំបើង) ដោយកម្លាំងប៉ះទង្គិច កម្លាំងកកិត ឬដោយកម្លាំងទាំងពីររួមគ្នា ។



### ការបោកដោយម៉ាស៊ីន

ដោយសារការបោកដោយដៃត្រូវការកម្លាំងពលកម្មច្រើន ម៉ាស៊ីនបោកដែលមានប្រភេទ និងទំហំខុសៗគ្នាជាច្រើន ត្រូវបានគេចាប់ផ្តើមប្រើប្រាស់ ។ អាស្រ័យទៅនឹងប្រព័ន្ធកសិដ្ឋាន ការអនុវត្តន៍បច្ចេកទេសក្រោយពេលប្រមូលផល និងហេដ្ឋារចនាសម្ព័ន្ធម៉ាស៊ីនបោកដែលមានទំហំខុសៗគ្នា ត្រូវបានគេផលិតឡើងចាប់ពីម៉ាស៊ីនតូចដែលអាចលើក

ឬសែងបាន ដោយមិនមានភ្ជាប់ប្រព័ន្ធសម្អាត រហូតដល់ម៉ាស៊ីនធុនធំ ដែលអូសសណ្តោងដោយត្រាក់ទ័រ (ថៃ) ។ ការបោកស្រូវអាចធ្វើឡើងនៅនឹងវាលស្រែផ្ទាល់នៅជិតវាលស្រែ ឬនៅនឹងផ្លូវដែលនៅជិតវាលស្រែនោះ ។

**ការបោកដោយដៃ**

**ការបែនដោយជើង ឬបញ្ជាន់**

ប្រើជើង ឬ សត្វពាហនៈ សម្រាប់បែន ឬបញ្ជាន់ ដោយពង្រាយស្រូវលើលាន ។ នៅតំបន់ខ្លះ ការបញ្ជាន់ស្រូវត្រូវបានគេប្រើប្រាស់ត្រាក់ទ័រជំនួសវិញ ។



**ការបោកផ្ទប់គ្រែ ឬ ក្តារ**

គ្រាប់ស្រូវបានផ្តាច់ចេញពីដើមដោយការវាយទង្គិចកណ្តាប់ស្រូវទៅផ្ទប់នឹងគ្រែឫស្សី ក្តារបោក ឬសម្ភារៈរឹងផ្សេងទៀតដូចជា ធុងដែកដែលប្រើសម្រាប់ដាក់ប្រេង (ហ្វុយប្រេង ) ។



**ម៉ាស៊ីនបោកធាក់ដោយជើង**

ដាក់ចុងកណ្តាប់ស្រូវទៅលើត្បាល់បោកដែលធាក់បង្វិលដោយជើង រួចទប់ឲ្យនឹង ពេលនោះធ្មេញវានឹងទាក់ផ្តាច់គ្រាប់ស្រូវពីចំបើង ។ ការប្រើប្រាស់ឧបករណ៍នេះចាំបាច់ត្រូវធ្វើការសម្អាតគ្រាប់ស្រូវ បន្ទាប់ពីបោករួចពីព្រោះកម្ទេចចំបើង សារធាតុលាយឡំផ្សេងៗធ្លាក់ទៅនិងនៅលាយឡំជាមួយគ្រាប់ស្រូវល្អ ។

